# ទស្សនវិជ្ជាសង្គមនិងទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈរបាំត្រុដិ

*ដោយៈ លោក* **ឈុន ផារ៉េន**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

*ជារៀងរាល់ឆ្នាំ របាំត្រុដិ ដែលជារបាំប្រជាប្រិយ ខ្មែរតាំងពីបុរាណ បានទទួលការចាប់អារម្មណ៍ កាន់តែខ្លាំងឡើង ពីសំណាក់ប្រជាពលរដ្ឋខ្មែរទូទៅ ពិសេសអ្នកដឹកនាំខ្មែរស្ទើរគ្រប់ស្ថាប័ន លើកលែងតែស្ថាបន័មួយចំនួនតូចប៉ុណ្ណោះ[1]។ យើងសង្កេតឃើញថា មុនថ្ងៃមហាសង្ក្រាន្ត ស្ថាប័នរដ្ឋ និង ឯកជនភាគច្រើនបំផុតបានរៀបចំពិធីសូត្រមន្តរំដោះគ្រោះលើកពាសីបន្ទាប់មកមានការរៀបចំសម្តែងរបាំត្រុដិ និងពិធីផ្សេងៗទៀតតាមលទ្ធភាពរបស់ខ្លួន។ របាំត្រុដិសឹងក្លាយជាមរតកវប្បធម៌ដ៏មានតម្លៃមិនអាចកាត់ថ្លៃបានរបស់ជាតិខ្មែរ ដោយសាររបៀបក្នុងការសំដែងមានភាពទាក់ទាញអារម្មណ៍ ធ្វើឱ្យរំភើបរំជីបរំជួលចិត្ត ព្រមទាំងបង្កប់នូវខ្លឹមសារដ៏មានឧត្តមគតិប្រកបដោយគតិបណ្ឌិតត្រឹមត្រូវទៀតផង។ តើរបាំត្រុដិនេះមានអត្ថន័យ និងផ្តល់ប្រយោជន៍អ្វីខ្លះដល់សង្គមខ្មែរយើង?*

## ១.អត្ថន័យនៃពាក្យ «ត្រុដិ»

*ពាក្យថា «ត្រុដិ» និង «ត្រស្តិ» ជាពាក្យ ២ មានន័យដូចគ្នា ថាៈ ការកាត់, ការផ្តាច់, ដំណើរកាត់ផ្តាច់ ។ ហេតុនេះហើយទើបមុនពេលដាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មីម្តងៗ ពាក្យថា «ត្រុដិ» និងពាក្យ «ត្រស្តិ ឬសូត្រមន្តផ្តាច់គ្រោះ»ត្រូវបានរំលឹកលាន់ឮកក្រើកក្នុងសង្គមខ្មែរ។ យោងតាមវចនានុក្រមខ្មែរ ជួន ណាត បោះពុម្ពលើកទី៥ នៅភ្នំពេញឆ្នាំ១៩៦៧ ដោយពុទ្ធសាសនបណ្ឌិត្យបញ្ជាក់ថាៈ*

*១.ត្រុដិ (អានថា ត្រុត)(ន.)(សំ.) ដំណើរកាត់, ការផ្តាច់។ ឈ្មោះភ្លេង, ចម្រៀងមួយប្រភេទសម្រាប់បណ្តាជនក្នុងខេត្រសៀមរាប គេលេងតែក្នុងឱកាសចូលឆ្នាំថ្មី។*

*២.ត្រស្តិ (អានថា ត្រស់)(ន.)(សំ.) ជាឈ្មោះព្រះរាជពិធីមួយប្រភេទ ធ្វើក្នុងវេលាយប់ ១៤ ពោចខែផល្គុន។ ក្នុងរជ្ជកាលពីបុរាណហៅថា ពិធីបញ្ជាន់ត្រស្តិ, សម័យឥឡូវហៅថា ពិធីភាណយក្ខ*

---

*[1] ស្ថាប័នខ្មែរខ្លះនិយមវប្បធម៌ចិន ដោយជំនួសរបាំត្រុដិទៅជារបាំលោតម៉ុងសាយ(ឬរបាំសត្វតោ)ដែលគេតែងសម្តែងនៅក្នុងឱកាសពិសេសធំៗ មានពិធីបុណ្យចូលឆ្នាំចិនជាដើម ព្រោះជឿថានឹងនាំមកនូវសំណាងល្អ។*

ឬ ពិធីសូត្រភាណយក្ខ។ ក្នុងព្រះរាជពិធីនេះ សំដៅយកសេចក្ដីថា "ដំណើរផ្ដាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី"។ កាលពីក្នុងសម័យបុរាណលោកហៅព្រះរាជពិធីនេះថា ពិធីត្រុដិ ឬ ពិធីបញ្ជាន់ត្រុដិ ហើយក្លាយមកជាពាក្យថា ត្រស្ដិ ។ ពិធីបញ្ជាន់ត្រស្ដិនេះពីបុរាណជាន់ដើម ចួនណាលោកហៅថា ពិធីសម្ពច្ឆរច្ឆិន្ទ ឬ សម្ពច្ឆរច្ឆិន្ទពិធី ឬ "ពិធីផ្ដាច់ឆ្នាំ"[2] ។ ក្នុងពិធីត្រស្ដិ ព្រះសង្ឃខាងពុទ្ធសាសនា តែងសូត្រភាណយក្ស (ឬអាដានាដិយបរិត្ត ឬអាដានាដិយ[3])។

## ២.ដើមកំណើតរបាំត្រុដិ[4]

ដោយសាររបាំនេះ ជារបាំប្រជាប្រិយ គេមិនអាចដឹងអំពីឈ្មោះអ្នកនិពន្ធ និងគោលបំណងពិតប្រាកដរបស់គាត់ពីដំបូងបានឡើយ។ មានទស្សនៈផ្សេងៗគ្នាដែលខំព្យាយាមបកស្រាយអំពីគោលបំណងដើមនៃរបាំត្រុដិ ទៅតាមការយល់ដឹងរៀងៗខ្លួន។

១.តាមឯកសារសម្ដេចព្រះវនរ័ត អ៊ីវ-ទូតះ

សេចក្ដីដំណាលថា មានត្រកូល អ្នកនេសាទម្នាក់ឈ្មោះ ប៊ុន ប្រពន្ធឈ្មោះ នាង ឧមា ភូមិលំនៅ នៅជិតស្រុកសាវត្ថី និស្ស័យជាមនុស្សកាចរឹងរឹងរូស។ គាត់ជាមនុស្សកម្សត់ទាល់ក្រ តែងតែបរបាញ់សត្វម្រឹកបក្សី នេសាទទាំងផ្លូវទឹក ផ្លូវគោក យកមកចិញ្ចឹមជីវិតរៀងរាបដរាបមក។ វេលាថ្ងៃមួយនោះ គាត់រៀបប្រដាប់ប្រដាធ្នូ ស្នា ព្រួញ ជ័រធក់ កាំបិតស្នៀត និង វត្ថុអ្វីៗ ទៀត តាមទម្លាប់ព្រាន។ នាងភរិយាក៏ចាត់ចែងម្ហូបចំណី បាវីស្លាប្រគល់ឱ្យប្ដី ។ ព្រានចេញដំណើរត្រាច់រង្គាត់ កាត់ព្រៃរំលងដងស្ទឹង ឆ្ងាយទៅៗ ពុំមានប្រទះម្រឹកណាមួយសោះ នាំព្រាននឹកថា ប្រហែលជាអស់លោកទេពារក្ស លោកបំបិទបំបាំងបង្វែងដាន មិនឱ្យឃើញ ហើយ។ បើដូច្នោះ ព្រានក៏ចាត់ចែង ធ្វើជារានទេពតា ៣ ថ្នាក់ តម្កល់ នូវ ប្រដាប់ប្រដាពលីការ សុំ លាភ សុំជ័យ ឱ្យបានជួបម្រឹក។ បន្ទាប់ពី បួងសួងរួចហើយ ព្រានធ្វើដំណើរតទៅមុខទៀត ស្រាប់តែ ប្រទះប្រើសមាសមួយភ្លឺឆ្អិនឆ្អៅ គឺរោមសុទ្ធតែជាសរសៃមាស ស្នែងជាកែវភ្លឺប្រាលរន្ទាល។ ព្រានត្រេកអរឥតឧបមា ពួនលបបំបាំងអាត្មាបាញ់បានប្រើសនោះហើយមីម្នាយកកាំបិតព្រាទៅកាត់យកស្នែង ពន្ធះស្បែកមូរទុកមួយដុំ។ អារសាច់ដោតចង្រ្កមូលរែក ដោយសេចក្ដីត្រេកអរដើរវិលត្រឡប់មកផ្ទះវិញ។ មកដល់ហើយ ដោយឃើញថាប្រើសនេះល្អណាស់ក៏នាំយកស្បែក និងស្នែងទៅថ្វាយស្ដេច។ ព្រះបាទ ព្រហ្ម ទត្តទ្រង់យល់ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទើបប្រទាន

[2] ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧។

[3] ធ្វើតាមរឿងរ៉ាវដែលមានដំណាលនៅក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ ឆដ្ឋភាគ បាដិកវគ្គ។

[4] សូមមើល ចាបពិន, *របាំប្រជាប្រជាប្រិយខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤ ទំព័រ៣១-៣៩។

យសដល់ នាយព្រាន ជាចៅហ្វាយខេត្ត។ ចាប់ពីថ្ងៃនោះមក ព្រាន ប៊ុន ឡើងយសជាចៅហ្វាយខេត្ត នាង ឧមា ជាជំទាវ ហើយក៏បង្កឱ្យមានក្រុមរបាំ និទានពី ព្រានដើរបរបាញ់ម្រឹក ដូចមាន ការរៀបចំក្នុងរង់ត្រុដិ សព្វថ្ងៃនេះ។

២.តាមសេចក្ដី ឱ្យការណ៍ពីលោក ឡុង សាន់ នៅបាត់ដំបង៖ មានសេចក្ដី ដំណាល មួយទៀតថា របាំត្រុដិនេះកើតឡើងតាមហេតុភេទដែលមាន ឡើងនៅសម័យ ដែលព្រះ សម្មាសម្ពុទ្ធនៅជា ពោធិសត្វ មុននឹងត្រាស់ដឹងព្រះអង្គទ្រង់ចេញ សាងបព្វជ្ជា។ ពេលនោះមារាពធិពជបានដំណែងក្លែងខ្លួនជា សត្វប្រើស មកពរាំង ស្ទាក់ផ្លូវព្រះអង្គ កុំឱ្យព្រះអង្គយាងទៅមុខបាន។ ព្រះពោធិសត្វ ទ្រង់តាំង អធិដ្ឋាន ឡើងក៏ក្ដៅដល់ទេវលោកមួយរំពេច ព្រះព្រហ្ម ព្រះឥន្ទ ទេវតា ទាំងឡាយចុះមកដំណែងភេទជា ង៉ោះ លបបាញ់ ប្រើសដែលជាមារាពធិពជក្លែងភេទនោះស្លាប់បាត់ទៅ។ រួចហើយ ពពួកទេវតាទាំងអស់នេះ ក៏នាំគ្នាដង្ហែព្រះអង្គ ធ្វងស្ទឹង អនោមា ទៅសាងព្រះផ្នួសសម្រេចបំណងទៅ ដោយមានក្មេងមហោស្រពរងំតាមដងផ្លូវ។ ដូច្នេះ បានជា គេយករឿងនោះ មកសាងជារបាំត្រុដិឡើង គឺ ដងកញ្ជារ ជាឆ័ត្រ ឬជាក្ងស់បើកបាំងព្រះពោធិសត្វ ពួកក្មេងជាទេពតា ឯនាងរាំជាទេពអប្សរ ហែហម ប្រើស ទន្សោង ជាមារ និង ព្រាន រួម ទាំងមនុស្សព្រៃ ជា ង៉ោះទេពតាការឡា។ តាមពិតរឿងបែបនេះ មិនឃើញមានក្នុងពុទ្ធប្បវត្តទឡើយ។

៣.តាមឯកសារលោក សុក មេភូមិគោកក្រសាំង ខេត្តសៀមរាប៖ គេលេង របាំត្រុដិដោយមានជំនឿថា នៅ តាមស្រុក ជិតឆ្ងាយយូរៗម្ដងរមែងមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក ប្រសិនណាជាសត្វព្រៃចូលស្រុកហើយ នឹងកើតឧបទ្រពចង្រៃបែបណាមួយជាមិនខាន។ ហេតុនេះបានជាមានទម្លាប់ថា បើឃើញសត្វព្រៃ ចូលស្រុកគេនាំគ្នាប្រោះព្រំប្រេងម្សៅឱ្យសត្វនោះ ហើយសុំពរជ័យពីសត្វទាំងនោះវិញ ដើម្បីរកឱកាសបង្កក់ប្រសិទ្ធិចំពោះសត្វព្រៃឱ្យ ហើយស្រេចក្នុងមួយឆ្នាំៗយ៉ាងនេះហើយបាន ជាអ្នកស្រុកដែលមានជំនឿដូច្នេះ ក៏បង្កើត ល្បែងត្រុដិនេះឡើង។ ហេតុនេះរង់ត្រុដិ ត្រូវ មានប្រើស ទន្សោង ក្ងោក សុទ្ធសឹងជាសត្វព្រៃ មកបង្ហាញខ្លួន ឱ្យអ្នកស្រុក អ្នកភូមិប្រោះព្រំ ប្រេង ម្សៅ ចងដៃ អំបោះ កម្រង ឱ្យទានជាលុយកាក់ទៅធ្វើបុណ្យរំដោះគ្រោះ ឱ្យស្រេចហើយតែម្ដងទៅដោយ មានជំនឿថាប្រសិនជាមានសត្វព្រៃ ចូលមកក្នុងស្រុកទៅថ្ងៃមុខទៀត ក៏គេបានប្រកបពិធីនេះរួចស្រេចទៅហើយដែរ ដូច្នេះគេជឿថា គ្មានចង្រៃឧបទ្រពអ្វីអាចកើតឡើងទៀតទេ។

៤.ឯកសារខ្លះទៀតថា៖ កាលពីជំនាន់បុរាណ ជនជាតិសំរែ បាននាំយករបាំត្រុដិទៅលេងថ្វាយព្រះរាជា នៅរៀងរាល់ពេលបុណ្យចូលឆ្នាំ ដើម្បីថ្វាយព្រះពរ សួស្ដីសិរីមង្គល។ ជនជាតិសំរែ ជាមនុស្សជាន់ដើមមួយពួកដែលរស់នៅលើ

ទឹកដីសុវណ្ណភូមិចាស់ តាំងអំពីដែនដីនេះពុំទាន់ទទួល អារ្យធម៌ពីប្រទេសឥណ្ឌានៅឡើយ។

## ៣.សម្រង់ខ្លឹមសារខ្លះក្នុងចម្រៀងរបាំត្រុដិ

មានទស្សនៈយល់ថា កាលពីបុរាណ ខ្មែរលេងរបាំត្រុដិនេះ នៅពេលរាំងស្ងួត, រដូវចូលឆ្នាំ, គ្រោះចង្រៃឬសត្វព្រៃចូលស្រុក និងអង្គាសប្រាក់។ យើងឃើញមានចម្រៀងដែលទាក់នឹងការសុំទឹកភ្លៀងឬពិធីសុំទឹកភ្លៀង[5] និងចម្រៀងបុណ្យចូលឆ្នាំជាច្រើនដែរ ប៉ុន្តែមិនមែនជាទំនុកច្រៀងដែលមានក្នុងខ្លឹមសារសម្រាប់របាំត្រុដិឡើយ។

ចំណែកខ្លឹមសារចម្រៀងរបាំត្រុដិដេញសត្វព្រៃពេលមានឧបទ្រពចង្រៃ ឬ មានសត្វព្រៃវត់ចូលស្រុកភូមិ មានដូចជា៖

១.«ទន្សោងគោនប់ៗ ចេញស៊ីតែយប់ ថ្ងៃវាពួនព្រៃ។ ទន្សោងទន្សែៗ ទន្សោងចង្រៃ មិនចេះដល់គ្នា។ ទន្សោងគោបាៗ រកបានទឹកថ្លា ដល់គ្នាឲ្យមើល។ រមាំងគាងអើយៗ ស៊ីរាំងគន្ធង វាដេញដល់បង ដួលផ្កាប់ដួលផ្ងារ»។

២.«រមាំងស្នែងកែក ស៊ីបែកពីហ្វូង រមាំងស្នែងស្រួង វែងហ្វូងបែកខ្ចាយ»។

រីឯ ខ្លឹមសារចម្រៀងរបាំត្រុដិ សម្រាប់កោសរូសសុំទេយ្យទានដើម្បីប្រមូលលុយយកទៅសាងសង់អ្វីមួយ មានដូចជា៖

៣.«នៃអើយកុំតោត ជញ្ជាំងស្លឹកត្នោត គង់មានថ្នាំខ្លាំង បានមួយបារី គង់មានកម្លាំង គាត់មានថ្នាំខ្លាំង មូលដាក់ជើងពាន» ។

៤.«កញ្ញារខ្ញុំដាច់ បានខ្សែអ្វីចង អំបោះមួយកម្រង ចងដៃកញ្ញារ។ ខ្ញុំសុំទានប្រាក់ ៗ ត្បិតមានធុរៈ ធ្វើស្គរគេបែក បើអ្នកមិនជឿ ទៅមើលបំណែក ធ្វើស្គរគេបែក ឯលិចស្វាយជ្រុំ»។

៥.«ចិញ្ចាត់ចិញ្ចេង ៗ ចិញ្ចាត់លេងៗ ក្រែងបានលុយកាក់» ។

ក្រៅពីនេះ ឃើញមានចម្រៀងរបាំត្រុដិសម្រាប់ឱ្យពរដល់អ្នកដាក់ទានដូចជា៖

៦.«អាដែងគ្នាយើង គាត់សូត្រអំបោះ គាត់ឲ្យយើងអស់ យើងឱ្យពរគាត់។ ឱ្យយសឱ្យយ ឱ្យពរទៀងទាត់ ឱ្យបានមូលមាត់ កូនចៅផងក្តី។ ឱ្យបានកូនប្រុស ជាមុខមន្ត្រី ឲ្យបានកូនស្រី ទំកីចម្ងាក់។ កាលកូនចេះដឹង ចេះដុលចេះប៉ាក់ ចេះទុកចេះដាក់ បម្រើម្តាយស្រី។ កាលកូនចេះដឹង ចេះអុំចេះស្នៃ ចេះត្បាញរវៃគោមគាត់។ បានមាសដូចចាក់ បានប្រាក់ដូចគរ បានខ្ញុំកំដរឆ្វេងស្តាំ» ជាដើម។

បច្ចុប្បន្ន ក្រុមរបាំត្រុដិខ្លះបានចេញសម្តែងនៅពេលរាំងរីសគ្មានភ្លៀងដោយមានដាក់សត្វឆ្មាជំនួសសត្វសត្វនានា ហើយប្រើទំនុកច្រៀងផ្សេងអំពីរបាំត្រុដិ។ ខ្លឹមសារចម្រៀងរបាំនេះ

[5] សូមមើល ពិធីសុំទឹកភ្លៀងមួយបែប ដោយ ជី រដ្ឋា, ស៊ិន ចាន់ដឹប, ហួត សំណាង តាមអាស័យដ្ឋាន https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-som-terk-pleang-mouy-beb.html

សម្រាប់កោសរូសសុំទេយ្យទានដើម្បីប្រមូលលុយយកទៅធ្វើអ្វីមួយ មានដូចជា៖ «ចៅសុំទឹកភ្លៀង ភ្លៀងតិចចៅមិនយក ភ្លៀងខ្លាំងៗមកឱ្យស្រូវបែកគុម្ព» ជាដើម។ ឧទាហរណ៍ នៅខេត្តសៀមរាប នៅឆ្នាំដែលខ្សត់ភ្លៀង ក្រុមរបាំត្រុដិ លោក តង់ មុត តែងចេញសម្ដែង «របាំត្រុដិនាងម៉េវ» តាមភូមិស្រុកដើម្បីសុំទឹកភ្លៀង។ ក្នុងការសម្ដែងរបាំនេះ អ្នកសម្ដែងយកសត្វឆ្មារស់ដាក់ក្នុងទ្រុង និងសែងដោយតួយក្សពីរនាក់។ ក្រៅពីនេះ មានអ្នកកាន់ឈ្នាងម្នាក់ និងអ្នកកាន់ល្អីម្នាក់ ចាំជញ្ជាត់និងដាក់ប្រាក់ដែលបានពីអ្នកភូមិ។ ការសម្ដែងនេះលាន់ឮរំពងពេញភូមិ តាមរយៈសំឡេងដែលចេញពីការលេងភ្លេង។ ក្នុងនោះមានអ្នកកូតទ្រម្នាក់ អ្នកវាយស្គរដៃពីរនាក់ អ្នកគោះកញ្ចែពីរនាក់ និងអ្នកច្រៀងម្នាក់។ ពេលកំពុងរាំរបាំនេះ អ្នកភូមិតែងយកទឹកស្រោចលើឆ្មាឬបាញ់ទឹកដាក់អ្នកសម្ដែងគ្រប់រូប។ នេះជាសញ្ញានៃភាពត្រជាក់ត្រជុំដោយរំពឹងថានឹងមានភ្លៀងធ្លាក់ក្នុងពេលឆាប់ៗ[6]។

## ៤.សង្ខេបចម្រៀងរបាំត្រុដិ

មានក្រុមរបាំត្រុដិ ដូចជា ក្រុមរបាំត្រុដិសច្ចធម៌ប្រវត្តិសាស្ត្រ (១៩៦៨) ក្រុមរបាំត្រុដិសមាគមចលនាវប្បធម៌(២០១៨), ក្រុមរបាំត្រុដិវត្តសុរិយា(២០២១) ជាដើម ដែលតែងតែលេងនិងច្រៀងចម្រៀងរបាំត្រុដិ មានលំនាំ និងអត្ថន័យដូចមានសេចក្ដីក្នុងអត្ថបទនៃគេហទំព័រFresh News ដែរ។ ខាងក្រោមនេះ ជាសេចក្ដីសង្ខេប ដោយផ្អែកទាំងស្រុងលើអត្ថបទចម្រៀងដើមដែលដកស្រង់ពីគេហទំព័រ Fresh News (សូមមើលឧបសម្ព័ន្ធ១)។ ដើម្បីងាយស្រួលយល់អត្ថន័យ យើងមិនបានបង្ហាញពីទំនុកច្រៀងទេ ប៉ុន្តែគ្រាន់តែរក្សាលំនាំកាព្យខ្លះៗប៉ុណ្ណោះ។ ទម្រង់ចម្រៀងនៃរបាំនេះមាន៣វគ្គ គឺ ១.ជម្រាបសួរដើម្បីសុំអនុញ្ញាតសម្ដែងត្រុដិ ២.បង្ហាញគំនិតទស្សនៈពិតប្រាដកនៃត្រុដិ ៣.ការជម្រាបលា។

***វគ្គទី១.*** ត្រុដិខ្ញុំមកដល់ហើយ ដល់ក្រៅរបង រទេះគោផង ចង្រ្កង់ខ្សែទាម។ ឈរឈប់នៅក្រៅ ស្រែកហៅទៅថ្កាន ជម្រាបសូមទាន សុំព្រលានលោកឈរលេង។ គ្នាខ្ញុំច្រើនណាស់ គគ្រឹកគគ្រេង សុំព្រលានលោកឈរលេង លេងបានដែរឬទេ?

***វគ្គទី២.*** ប្រើសមួយប្រឹងរត់ ព្រានព្រៃដេញស្កាត់ ប្រើសភ័យរត់បាត់ ព្រានបាញ់ខុសម្ដង។ ប្រើសឡកឡយដាក់ព្រាន ព្រានខឹងពេកហួង លើកធ្នូផ្គង់ ប្រើសភ័យរត់បាត់។ ផ្អើលអស់ពួកយក្សដេញស្ទាក់ចាប់ម្រឹក ទៅមុខក្រោយទើស សន្ធឹកពេញព្រៃ។ យក្សយាសដាវកាប់ ទន្តិចដាវជាប់ ប្រើសភ័យរត់បាត់ ឡកឡយដាក់យក្ស។ ព្រាយស្រីក្រចកវែង ចេញរាំទន់ទែន ដេញស្ទាក់ចាប់ម្រឹក សន្ធឹកពេញព្រៃ។ ក្ងោកចេញជួយព័ទ្ធ ប្រើស

[6] ថោង ប្រណិ, របាំត្រុដិនាងម៉េវ, ផលិតដោយសារព័ត៌មានឌីជីថលថ្មីៗ https://www.youtube.com/watch?v=Zv7TAslm19s

ផុតវាសនា ទន្សោងក៏ចេញរ៉ា ព្រានបាញ់ប្រើស ស្លាប់[7]។

**វគ្គទី៣.** ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណឹងហ្អង មានរទេះគោផង រៀបដំណើរទៅ។

អត្ថន័យក្នុងវគ្គទី១ គឺការស្វាគមន៍ និងការសុំអនុញ្ញាត ដោយគោរពគោលការណ៍ច្បាប់ ដើម្បីសុំទីតាំងក្នុងការសំដែងមតិដោយសេចក្ដីថ្លៃថ្នូរ។ អត្ថន័យក្នុងវគ្គទី២ បង្ហាញពីជោគជ័យដ៏ត្រចះត្រចង់របស់ព្រានក្នុងការបាញ់សម្លាប់ប្រើស ដោយមានការសហការពីក្ងោកនិងទន្សោង។ រីឯអន្តរាគមន៍ពីសភាវដទៃទៀត ដូចជា យក្ស និងព្រាយ ហាក់គ្មានឥទ្ធិពលក្នុងការកំចាត់ប្រើសនោះឡើយ។ អត្ថន័យក្នុងវគ្គទី៣.គឺ ជាការប្រកាសឈប់សំដែងមតិទស្សនៈ ដោយការជម្រាបលាប្រកបដោយសុជីវធម៌។

## ៥.សម្មតិកម្មលើខ្លឹមសារបទចម្រៀងរបាំត្រុដិ

ខណៈនេះ យើងដាក់ចេញនូវសម្មតិកម្មលើតួអង្គសំខាន់នៃរបាំត្រុដិ ដូចតទៅ៖ **១.ប្រើស** គឺសត្វ ចតុប្បាទព្រៃ ពួកក្ដាន់ រមាំង ដែលខ្មែរមិនចូលចិត្តផ្សាំងឱ្យក្លាយជាសត្វស្រុក ជាតំណាងព្រាហ្មណ៍សាសនា។ **២.ព្រាន** តំណាងប្រជាពលរដ្ឋជនជាតិខ្មែរដើមម្ចាស់ស្រុក មានជនជាតិសំរែជាដើម។ **៣.យក្ស** តំណាងសភាវមើលមិនឃើញដោយភ្នែក, ជាអមនុស្ស មានទេព្ដានៅលើដី, ទេព្ដាតាមផ្ទះតាមភូមិ, អសុរ, បិសាចជាដើម ទោះមានចិត្តល្អក្ដី មានចិត្តអាក្រក់ក្ដី ដែលពួកមនុស្សរាប់អានធ្វើពលិការបូជា សែនព្រេន ជាតំណាងជំនឿអ្នកតា ក្នុងជំនឿជីវចល។ **៤.ព្រាយ**[8] ជាបិសាច តំណាងដូនតា ក្នុងជំនឿជីវចលខ្មែរ។ **៥.ក្ងោក** (ជាសត្វបក្សីមួយប្រភេទ មានរោមស្លាបដុះនៅលើក្បាលដូចជាផុក មានផ្ទាល់ដូចមាន់ សំណុំកន្ទុយធំវែងពន្លាតដូចព្រះអាទិត្យ) តំណាងទ្រឹស្ដីមគមន៍វិជ្ជាផ្សេងទៀត មានវិទ្យាសាស្ត្រធម្មជាតិ សង្គម នយោបាយ សេដ្ឋកិច្ចជាដើម។ ៦.ទន្សោង ជាសត្វជើង៤ ពួកគោព្រៃ ដែលជនជាតិអាស៊ីចូលចិត្តផ្សាំងជាសត្វស្រុក តំណាងពុទ្ធសាសនា។

## ៦.ទស្សនវិជ្ជាសង្គមនិងនយោបាយតាមរយៈរបាំត្រុដិ

ប្រជាជនខ្មែរភាគច្រើននៅតែមានជំនឿជាក់ថា របាំត្រុដិ ជារបាំមួយធ្វើឡើងដើម្បីសុំទឹកភ្លៀងដ៏ពេញនិយម។ លើសពីនេះ វាបានបង្កប់

---

[7] បច្ចុប្បន្ន មានរៀបចំឱ្យប្រមុខនៃទស្សនិកជន បានយកទឹកមន្ត មកប្រស់ឱ្យប្រើសរស់ឡើងវិញ។

[8] ព្រាយ ជា ភូត, បិសាចពួកមួយដែលគេច្រើនជឿថាតែងចូលជ្រែកយាយីមនុស្សឲ្យឈឺចាប់។ គេជឿឬចាត់ទុកថាពន្លឺដែលភ្លឺព្រោងព្រាយរតាយៗ ឬភ្លឺធ្លោ ឯអាកាសក្នុងវេលាយប់ម្ដងៗ ជាព្រាយហោះ។ ការស្លាប់ដោយសម្រាលកូនពុំរួចឬស្លាប់ទាំងកូននៅក្នុងផ្ទៃ គេហៅថាស្លាប់ព្រាយ ហើយក្លាយទៅជាព្រាយបំពេរកូន។

អត្ថន័យ ទស្សនវិជ្ជាសង្គមនិងនយោបាយ យ៉ាងជ្រាលជ្រៅច្បាស់លាស់ ស្របនឹងដំណាក់កាលវិវត្តន៍នៃប្រវត្តិសង្គមខ្មែរ ព្រោះថា ដំណើររឿងក្នុងរបាំត្រុដិ មានភាពស៊ីគ្នាទៅនឹងហេតុការណ៍ទាំងឡាយនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា[9]។

ខ្លឹមសារគោលនៃរបាំត្រុដិនេះ គឺមានន័យថា ជាការសម្លាប់នូវអ្វីដែលជានិមិត្តរូបនៃភាពអនារ្យធម៌បរទេសណាដែលចង្រៃ សម្រាប់ស្រុកភូមិ ប្រទេសជាតិរបស់យើង ដូចដែលមានការសម្លាប់តួអង្គ សត្វប្រើស នោះជាឧទាហរណ៍[10]។

ដូចបានជ្រាបហើយថា លទ្ធិសាសនាក្នុងសង្គមខ្មែរដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែករក្សាសណ្ដាប់ធ្នាប់ របៀបរបប សន្តិសុខសង្គម រហូតដល់សន្តិភាពប្រទេសជាតិទាំងមូលទៀតផង។ ការផ្លាស់ប្តូរសាសនាក្នុងសង្គមខ្មែរ តែងកើតឡើងទៅតាមជំនឿរបស់ព្រះមហាក្សត្រ ដែលគ្រប់គ្រងតាមទេវរាជ ឬពុទ្ធរាជ ឬបុគ្គលនិយម។

[9] តាមទ្រឹស្តីអក្សរសិល្ប៍ អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គម សង្គមបែបណាអក្សរសិល្ប៍បែបនោះ ជាពិសេសរបាំត្រុដិដែលជាអក្សរប្រជាប្រិយប្រពៃណី។

[10] ប្រសាសន៍បណ្ឌិត កេង វ៉ាន់សាក់ ក្នុងបទសម្ភាសរបស់លោក សំ បូរិន ។ លោក អះអាងថា ខ្មែរមានសាសនាដី មានភាសា អក្សរសាស្ត្រ របស់ខ្លួន។ លោកឱ្យតម្លៃខ្ពស់លើរឿងរាមកេរ្តិ៍ខ្មែរ ដែលសរសេរដោយខ្មែរសូមស្តាប់ អាស័យដ្ឋាន៖ https://www.youtube.com/watch?v=WzBnxkJfvh8 &t=1 6 7 3 s ឬ https://www.youtube.com/watch?v=WzBnxkJfvh8

ប្រជាជនពុំមានអំណាចជ្រើសរើសសាសនាសម្រាប់ប្រទេសឡើយ សូម្បីតែសិទ្ធិសម្តែងមតិក៏ពិបាកធ្វើដែរ។ ទំនោរខ្លាំងក្លានៃការសម្តែងឆន្ទៈជំនឿរបស់មហាជន អាចត្រូវបានបង្ហាញតាមវិធីផ្សេងៗដែលមិនអាចស្គាល់ឈ្មោះអ្នកនិពន្ធ ដូចជាតាមរយៈ បទចម្រៀង របាំ រឿងនិទាន អក្សរសិល្ប៍ប្រជាប្រិយ ជាដើម។

តាមរយៈប្រវត្តិនៃការផ្លាស់ប្តូរសាសនា នាំអាចឱ្យយើងយល់អំពីទស្សនវិជ្ជាសង្គម និងនយោបាយខ្មែរតាំងពីអតីតកាលបានដូចតទៅៈ ខ្មែរមានទ្រឹស្តីដឹកនាំស្រុកទេសរបស់ខ្លួនតាមជំនឿអ្នកតា ឬទស្សនៈជីនិយម ដោយផ្អែកលើគោលគំនិត «មេ បា ព្រះ តា ចៅ»[11]។ ជាក់ស្តែងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសង្គមអក្សរសាស្ត្រ វប្បធម៌ជាដើម សុទ្ធតែបង្កប់ដួងព្រលឹងមេបា ព្រះ តា ចៅ យ៉ាងរស់រវើក ដូចជាឈ្មោះ មេក្នុងប្រាសាទមេបុណ្យ, បាក្នុងប្រាសាទបាពួន, ព្រះក្នុងប្រាសាទព្រះគោ, តាក្នុងប្រាសាទតាព្រហ្ម, ចៅក្នុងប្រាសាទចៅសាយ, និងក្នុងបរិបទដទៃទៀត ដូចជា មេភូមិ, បារាយណ៍, ព្រែកតាទែន, ជាដើម។

[11] «មេ បា តា ព្រះ ចៅ» គឺជាទស្សនៈអំពីជំនឿខ្មែរ មុនពេលទទួលអរិយធម៌ឥណ្ឌា ដែលលើកឡើងដោយលោក កេង វ៉ាន់សាក់ នៅឆ្នាំ ១៩៧២ តាមវិទ្យុជាតិខ្មែរ ក្នុងយុទ្ធនាការឃោសនារកសម្លេងឱ្យសេនាប្រមុខ លន់ នល់ អំឡុងពេលបោះឆ្នោតរើស ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ។

ចំពោះលទ្ធិព្រាហ្មណ៍សាសនា ដែលនាំចូលតាមរយៈព្រះបាទហ៊ុនទៀន និង ឈ្មួញពីប្រទេសឥណ្ឌា មានលក្ខណៈខុសគ្នាពីទំនៀមទម្លាប់ប្រពៃណី អ្នកស្រុកដើម ជាពិសេសជំនឿស្ដីអំពីអាទិទេព ជាអ្នកបង្កើតនិងបំផ្លាញលោក ការបែងចែកវណ្ណៈពូជសាសន៍ វង្សត្រកូល បណ្ដាសា ព្រហ្មលិខិត ជាដើម។ ព្រាហ្មណ៍សាសនាមាននិកាយបីធំៗ គឺ និកាយព្រះព្រហ្ម វិស្ណុ សិវៈ ហើយពួកនិកាយទាំងនេះតែងតែដណ្ដើមឥទ្ធិពលគ្នាទៅវិញទៅមក ដែលបង្កបញ្ហាជាច្រើនទៀតផង[12]។ នៅកម្ពុជា ដើម្បីបន្ថយជម្លោះនេះ អ្នកប្រាជ្ញខ្មែរបង្រួមព្រះវិស្ណុ និង សិវៈឱ្យទៅជាព្រះតែមួយ ដោយដាក់ឈ្មោះថា «ហរិហរៈ»។

ព្រះមហាក្សត្រិយ៍ជំនាន់ក្រោយមកទៀតមានការផ្លាស់ប្ដូរសាសនា គឺពី ព្រាហ្មណ៍សាសនាទៅជាពុទ្ធសាសនាមហាយាន និងក្រោយមកទៀតផ្លាស់ពីពុទ្ធសាសនាមហាយាន មកជាពុទ្ធសាសនាថេរវាទវិញ[13]។ ថ្វីត្បិតមានការខុសគ្នាខ្លាំងខាងទស្សនៈស្ដីអំពីតួអង្គព្រះពោធិសត្វយ៉ាងណាក៏ដោយ ក៏និកាយពុទ្ធសាសនាទាំងពីរ កម្របង្ហាញឱ្យឃើញជម្លោះស្រួចស្រាល់រវាងបរិស័ទ និងបរិស័ទណាស់ ប៉ុន្តែគេឃើញមានបដិវាទកម្មស្មុគ្រស្មាញ ការមិនយល់ស្របគ្នាខាងទ្រឹស្ដីនិងការបដិបត្តិ រវាងអ្នកដឹកនាំទេសនានៃនិកាយទាំងពីរជាដរាបរៀងមក[14]។

រីឯពុទ្ធសាសនា និង ព្រាហ្មណ៍សាសនា មានទស្សនៈផ្ទុយគ្នាស្រឡះអំពី ទ្រឹស្ដីអត្ថិភាពនៃអាត្ម័ន។ ព្រះពុទ្ធសាសនាមិនទទួលស្គាល់អាត្ម័ន (អត្តា) បែបព្រាហ្មណ៍សាសនាឡើយ។ តាមសច្ចភាពបរានុម័ត ព្រះពុទ្ធសាសនារកឃើញថា អ្វីៗទាំងអស់ជា អនត្តា។ ពុទ្ធសាសនា បង្រៀនមនុស្សឱ្យរស់នៅតាមគោលការណ៍ ផ្លូវកណ្ដាលឬមជ្ឈិមាបដិប្បទា ឬ អដ្ឋង្គិកមគ្គ ឬសីល-សមាធិ- បញ្ញា ដែលស្របគ្នានឹង លទ្ធិឬទ្រឹស្ដីវិទ្យាសាស្ត្រនយោបាយសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងរដ្ឋតាមរដ្ឋធម្មនុញ្ញតាមបែបទំនើបដែលមានលក្ខណៈវិទ្យាសាស្ត្រ[15] ដូច្នោះហើយទើបរដ្ឋធម្មនុញ្ញខ្មែរចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋរហូត

[12] ក្នុងរបាំត្រុដិ ច្រៀងថា៖ «រមាំងគាងអើយៗ ស៊ីរាំងគន្ធងវាដេញដល់បង ដួលផ្កាប់ដួលផ្ងារ»។ «រមាំងស្នែងកែកស៊ីបែកពីហ្វូង រមាំងស្នែងស្រួង វ័ធហ្វូងបែកខ្ចាយ»។ (សត្វរមាំង ឬ សត្វប្រើស ជំនួសគ្នាបាន)

[13] សូមមើល ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ១១៣-១១៤

[14] ក្នុងរបាំត្រុដិ ច្រៀងថា៖ «ទន្សោងគោនប់ៗ ចេញស៊ីតែយប់ ថ្ងៃវាពួនព្រៃ។ ទន្សោងទន្សៃៗ ទន្សោងចង្រៃ មិនចេះជល់គ្នា។ ទន្សោងគោបាៗ រកបានទឹកថ្លា ជល់គ្នាឲ្យមើល»។ (ទន្សោងឬគោព្រៃ ទីនេះតំណាង ពុទ្ធសាសនា)

[15] លទ្ធិឬទ្រឹស្ដីនៃការគ្រប់គ្រងរដ្ឋបែបទំនើបដោយមានរដ្ឋធម្មនុញ្ញ ទ្រឹស្ដីវិទ្យាសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ជាដើម ក្នុងរបាំត្រុដិតំណាងដោយសត្វក្ងោក។

មក[16]។ ពុទ្ធសាសនាបានជួយឃិតយោងជ្រោមជ្រែងរក្សាទុក និង រក្សាការពារអត្តសញ្ញាណជំនឿខ្មែរដើមថែមទៀតផង។ យើងឃើញថានៅតាមវត្តអារាមខាងពុទ្ធសាសនាតែងតែអនុញ្ញាតឱ្យមានខ្ទមអ្នកតា និង បានរក្សាទំនៀមទម្លាប់ ប្រពៃណីជំនឿដើមរបស់ខ្មែរជាដរាបរៀងមក។ ការរួបរួមរវាងទស្សនៈជំនឿខ្មែរដើម[17] ជាមួយទ្រឹស្តីដឹកនាំរដ្ឋទំនើបតាមវិទ្យាសាស្ត្រនយោបាយមានការដឹកនាំតាមរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ (មានសេរីឬកុម្មុយនីស្តជាដើម)[18] បានទាត់ចោលទាំងស្រុងនូវការគ្រប់គ្រងបែបសក្តិភូមិ លទ្ធិទេវរាជ របបដែលមានស្តេចដឹកនាំក្នុងនាមអាទិទេពសាសនាព្រាហ្មណ៍[19]។

ចំណែកទស្សនៈស្តីពីការប្រោសឱ្យរបបរាជានិយមរស់ឡើងវិញ គឺគ្រាន់តែជានិមិត្តរូបជាប្រពៃណីប៉ុណ្ណោះ ពោលគឺទុកឱ្យមានព្រះរាជាទ្រង់សោយរាជ ប៉ុន្តែមិនកាន់អំណាចឡើយ[20]។

## ៧.ផលប្រយោជន៍នៃបាំត្រុដិ

បាំត្រុដិមានប្រយោជន៍ធំធេងមិនអាចកាត់ថ្លៃបាន ព្រោះកាលណាគេសម្តែងរបាំនេះម្តងៗនាំឱ្យគេទទួលបាន៖

ក.ការបន្ថយភាពល្អក់កករ បំបាត់កង្វល់ចង្រៃក្នុងចិត្ត បង្កើតសេចក្តីសង្ឃឹមឡើងវិញហាក់មានសភាវៈខាងក្នុងនិងខាងក្រៅតាមជួយអន្តរាគមន៍។

ខ.បរិយាកាសសប្បាយរីករាយ បង្កើនស្មារតីសាមគ្គីផ្ទៃក្នុងស្ថាប័ន សង្គមជាតិ រហូតពិភពលោកទាំងមូល។

គ.អត្តសញ្ញាណជាតិខ្មែរ រក្សាកេរមរតកអំពីលទ្ធិជំនឿបុរាណ ដ៏មានតម្លៃក្នុងសិល្បៈវប្បធម៌ខ្មែរម្ចាស់ស្រុក ដែលមនុស្សគ្រប់ជំនាន់គ្រប់ជាតិសាសន៍ទទួលស្គាល់ និងកោតសរសើរ។

ឃ. ថវិកាដោះស្រាយបញ្ហាហិរញ្ញវត្ថុសម្រាប់ប្រយោជន៍សាធារណៈមួយគ្រាបន្ថែមលើផែនការគោលដៅខ្វះខាតណាមួយ ដូចជាការបំពេញបន្ថែមលើកសាងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា សាលារៀន កសាងអាគារ ទឹកន្ទេង ធ្វើបុណ្យទាន ជាដើម។

ង.បណ្តុះទម្លាប់អ្នកស្រុក ឱ្យមានចិត្តសប្បុរសធម៌ ចេះបរិច្ចាគទានក្នុងសហគមន៍ និងសង្គមជាតិ ជាដើម។

16 ពុទ្ធសាសសនា ជាសាសនារបស់រដ្ឋ មានចែងក្នុងរដ្ឋធម្មនុញ្ញ ចាប់ពីខ្មែរមានរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧ រហូតបច្ចុប្បន្ន លើកលែងតែ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមួយប៉ុណ្ណោះ។

17 ក្នុងរបាំត្រុដិតំណាងដោយ យក្ស និង ព្រាយស្រី។

18 ក្នុងរបាំត្រុដិ តំណាងដោយសត្វក្ងោក។

19 ក្នុងរបាំត្រុដិ តំណាងដោយសត្វប្រើស។

20 ក្នុងរបាំត្រុដិ ច្រៀងថា៖ «ក្ងោកចេញជួយព័ទ្ធ ប្រើសផុតវាសនា ទន្សោងក៏ចេញវ៉ា ព្រានបាញ់ប្រើសស្លាប់»។ នៅលើពិភពលោកបច្ចុប្បន្ន គ្មានរបបរាជានិយមដែលស្តេចទ្រង់សោយរាជ និងកាន់អំណាចផ្តាច់ការតាមលទ្ធិទេវរាជ(ស្តេចជាអាទិទេព)ទៀតឡើយ ។

## សន្និដ្ឋាន

តាមរយៈខ្លឹមសាររបាំត្រុដិនិងយោងតាមតថភាពប្រវត្តិសាស្ត្រ យើងអាចនិយាយបានថា ជំនឿជីវចលនិយម នៅមានឱកាសរស់រានមានជីវិតបន្តដើម្បីរក្សាអត្តសញ្ញាណរបស់ខ្មែរ ក៏ដោយសារនៅមានជនជាតិដែលមានឈាមជ័រនិងព្រលឹងជាខ្មែរនៅមានអត្ថិភាពនៅឡើយ។

ដោយសារឥទ្ធិពលវិទ្យាសាស្ត្រនយោបាយសេដ្ឋកិច្ច ដែលសង្គមខ្មែរបានស្គាល់ការគ្រប់គ្រងដឹកនាំរដ្ឋតាមបែបទំនើបដោយមានរដ្ឋធម្មនុញ្ញជាមូលដ្ឋាន និងឥទ្ធិពលពុទ្ធសាសនា យើងសង្ឃឹមថា អត្តសញ្ញាណជាតិខ្មែរនឹងបាត់បង់ដោយឥទ្ធិពលនៃលទ្ធិព្រហ្មណ៍សាសនាពីឥណ្ឌាឡើយ។ ទោះយ៉ាងណាក៏យើងនៅតែទទួលស្គាល់ថា លទ្ធិព្រហ្មណ៍សាសនា បានបន្សល់ទុកនូវមរតកវប្បធម៌សិល្បៈជាច្រើនដែរ ហេតុនេះទើបយើងកោតសរសើរគំនិតបញ្ញវន្តខ្មែរសម័យថ្មីដែលតម្រូវឱ្យមានការប្រោសសត្វប្រើសឱ្យរស់ឡើងវិញក្នុងរបាំត្រុដិ។

របាំត្រុដិជាកម្មសិទ្ធផ្តាច់មុខរបស់ខ្មែរ ដែលអាចចាត់ជាកេរដំណែលអារ្យធម៌មនុស្សជាតិមួយ។ វាអាចក្លាយជាបេតិកភណ្ឌវប្បធម៌ពិភពលោកនៅពេលអនាគត ប្រសិនគេយល់អត្ថន័យពិតរបស់វា។

## ឧបសម្ព័ន្ធ១ ៖ ចម្រៀងរបាំត្រុដិ

## ស្វែងយល់ពី «របាំត្រុដិ» ដែលខ្មែរយើងតែងលេងក្នុងឱកាសបុណ្យចូលឆ្នាំថ្មី

ដកស្រង់ពីគេហទំព័រ freshnewsasia.com នៅថ្ងៃ ១៦ មេសា ២០២៤។

https://www.freshnewsasia.com/index.php/en/knowledge/283979-2023-03-25-10-23-38.html

ហ្អា អ៊ើយ... កំប្លង់ៗអ្អើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំបង។ (ច្រៀងសាឡើងវិញច្រើនដង)

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ...ត្រុដិខ្ញុំមកដល់ហើយ... ដល់ក្រៅឱរបង រទេះឱគោផង ម្ចាស់អ្អើយចង្រង់ឱខ្សែ ទាមអ្អើយ...ណានាងណា....ចង្រង់ឱខ្សែទាម....។

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ...ឈរឈប់ឱនៅក្រៅ... ស្រែកហៅឱ្យទៅថ្កាន... ជម្រាបឱ្យសូមទាន ថ្ងៃអ្អើយសុំព្រលានលោកឈរលេង ណានាងណា....សុំព្រលានលោកឈរលេង។

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ... គ្នាខ្ញុំឱ្យច្រើនណាស់...គគ្រឹកឱគគ្រេង សុំព្រលានលោកឈរលេង ម្ចាស់អ្អើយ លេងបានឱ្យដៃរឬទេ.... ណានាងណា....លេងបានឱ្យដៃរឬទេ។

ហ្អា អ៊ើយ...ឱនៃកំប្លង់ៗអ្អើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំ បង។

សំឡេងព្រានស្រែកដេញព័ទ្ធប្រើសៈ ខ្វះស្រែក ព័ទ្ធៗៗ ទៅហើយៗៗ ដេញៗៗ ព័ទ្ធៗៗ

ហ្អា អ៊ើយ.... អឺៗអឺងអ៊ើយ.... ប្រើសុំមួយឱប្រឹងរត់ ព្រានព្រៃឱដេញស្កាត់ ប្រើសភ័យឱរត់បាត់ ថ្ងៃអ្អើយ ព្រានបាញ់ឱខុសម្តង ណានាងណា....ព្រានបាញ់ឱខុសម្តង។

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ...ប្រើសឡូកឡូយដាក់ព្រាន ព្រានខឹងឱពេកហ្អង លើកធ្នូឱផ្លូវផ្តង់ ម្ចាស់អ្អើយ ប្រើសភ័យឱរត់បាត់ ណានាងណា....ប្រើសភ័យឱរត់បាត់។

ហ្អា អ៊ើយ...ឱនៃកំប្លង់ៗអ្អើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំ បង។

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ... ផ្អើលអស់ឱពួកយក្ស ដេញស្ទាក់ឱចាប់ម្រឹក ទៅមុខឱក្រោយទើស ថ្ងៃអ្អើយ សន្ទឹកឱពេញព្រៃ ណានាងណា....សន្ទឹកឱពេញព្រៃ។

ហ្អា អ៊ើយ...អឺៗអឺងអ៊ើយ...យក្សយាសឱដាវកាប់ ទង្គិចឱដាវជាប់ ប្រើសភ័យឱរត់បាត់ ម្ចាស់អ្អើយឡូកឡូយ ឱដាក់យក្ស ណានាងណា...ឡូកឡូយឱដាក់យក្ស។

ហ្អា អ៊ើយ...ឱនៃកំប្លង់ៗអ្អើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំ បង។

*ហ្អាអើយ...អឺៗអឺងអើយ...ព្រាយស្រីក្រចកវែង ចេញរាំឱទន់ទែន ដេញស្ទាក់ឱចាប់ម្រឹក ថ្ងៃអ្ហើយសន្ទឹកឱពេញព្រៃ ណានាងណា....សន្ទឹកឱពេញព្រៃ។*

*ហ្អាអើយ...ឱនៃកំប្លង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗរ៉ា ឆារ៉ាមុំបង វើយៗក្រមុំ បង។*

*ហ្អាអើយ.... អឺៗអឺងអើយ.... ក្មោកចេញឱជួយព័ទ្ធ ប្រើសផុតឱវាសនា ទន្សោងក៏ចេញឱអើយរ៉ា ថ្ងៃអ្ហើយព្រានបាញ់ឱប្រើសស្លាប់ ណានាងណា....ព្រានបាញ់ឱប្រើសស្លាប់។*

*ហ្អាអើយ.... អឺៗអឺងអើយ.... ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណឹងហ្អង មានរទេះឱគោផង ថ្ងៃអ្ហើយរៀបដំឱណើរទៅ ណានាងណា...រៀបដំឱណើរទៅ។*

*ហ្អាអើយ.... ឱនៃកំប្លង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗរ៉ា ឆារ៉ាមុំបង វើយៗក្រមុំបង។ (ច្រៀងសាឡើងវិញច្រើនដង)។*

**ឯកសារយោង/គន្ថនិទ្ទេស**


១-ចាបពិន, *របាំប្រជាប្រជាប្រិយខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤

២-ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

៣-ត្រឹង ង៉ា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣

៤-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)